# កញ្ចប់ឧបករណ៍

ស្តង់ដារពិការភាព
សំរាប់ការអប់រំ



## ជំហានជំរាបបារម្ភនិងដោះស្រាយ តំអូញជាមួយសាលាអ្នក

ធនធាននេះជួយមាតាបិតានិងអ្នកថែរក្សាសិស្សដែលមានពិការភាព
អោយជំរាប លើកទៅថ្នាក់លើ
ហើយនិងដោះស្រាយបារម្ភជាមួយសាលារបស់គេ។

ធនធាននេះត្រូវបានបង្កើតរួមគ្នាដោយសិស្សនិងយុវជនដែលមានពិការភាព និងមាតាបិតា និងអ្នកថែរក្សារបស់គេ។

## អំពីធនធាននេះ

ធនធាននេះត្រូវបានទទួលមូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី។
វាត្រូវបានបង្កើតដោយសិស្សនិងក្មេងដែលមានពិការភាពនិងមាតាបិតានិងអ្នកថែរក្សារបស់គេ
រួមនឹងជំនួយពី**កុមារនិងយុវជនពិការនៅអូស្ត្រាលី** (CYDA)។

កញ្ចប់ឧបករណ៍នេះផ្តល់ព័ត៌មានទូទៅតែប៉ុណ្ណោះ។ វាមិនប្រហែលជាមិនបង្ហាញពីរបៀបប្រើច្បាប់ដល់កាលៈទេសៈរបស់អ្នកទេ។
វាមិនផ្តល់ឱវាទច្បាប់ទេ។

រដ្ឋាភិបាលអូស្ត្រាលីទទួលស្គាល់ម្ចាស់ទឹកដីដើមនិងអ្នកថែរក្សាស្រុកទូទាំងប្រទេសអូស្ត្រាលី។
យើងទទួលស្គាល់ដល់ទំនាក់ទំនងដ៏និរន្តន៍ជាមួយដី ទឹក និងសហគមន៍របស់គេ។
យើងសូមគោរពដល់ពួកគេនិងដល់ពួកចាស់ទុំពីអតីតកាលនិងបច្ចុប្បន្នកាល។
យើងសូមគោរពដល់ការអនុវត្តផ្នែកវប្បធម៌ ព្រលឹងវិញ្ញាណ និងការអប់រំនៃជនអាបូរិជិនី និងពួកកោះ
Torres Straight។

## កំណត់សំគាល់ពីភាសា

ធនធាននេះប្រើភាសាបុគ្គលមុន (ឧ. សិស្សដែលមានពិការភាព)។ ប៉ុន្តែវិធីនេះមិនសមនឹងមនុស្សគ្រប់រូប
ហើយមនុស្សជាច្រើនចូលចិត្តភាសាអត្តសញ្ញាណមុន (ឧ. សិស្សពិការ)។

វាសំរេចទៅលើបុគ្គលម្នាក់ៗ ដែលគេជ្រើសរើសសំគាល់ខ្លួនដោយរបៀបណានោះ។
យើងសូមលើកទឹកចិត្តអ្នកអោយសួរគេថាគេចូលចិត្តអ្វី។
យើងក៏ទទួលស្គាល់ប្រវត្តិសាស្ត្រដ៏ជ្រាលជ្រៅដែលនៅពីក្រោយពាក្យទាំងនេះដែរ។

ធនធាននេះគឺសំរាប់មាតាបិតានិងអ្នកថែរក្សាសិស្សដែលមានពិការភាព។ ពេលយើងនិយាថា ‘កូនអ្នក’
គឺមានន័យថាកូនណាដែលអ្នករ៉ាប់ទទួលខុសត្រូវ។

## ធនធានបន្ថែម

នេះគឺផ្នែកមួយនៃធនធានមួយក្រុម។
អ្នកអាចរកឃើញនៅក្នុងវែបសៃត៍របស់ក្រសួងអប់រំនៃរដ្ឋាភិបាលអូស្ត្រាលី ឬដោយស្កេនកូដ QR ។

ស្កេនកូដ QR

ធនធាននេះក៏មានជា Easy Read, Auslan និងភាសាផ្សេងៗមួយចំនួនទៀត។
អ្នកអាចចូលមើលសំណេរទាំងនោះនៅវែបសៃត៍របស់ក្រសួងអប់រំនៃរដ្ឋាភិបាលអូស្ត្រាលី ឬដោយស្កេនកូដ QR។

***កំណត់សំគាល់មាតិកា:*** *ធនធាននេះនិយាយពីការរើសអើង។ សូមទូរស័ព្ទមក Lifeline តាមលេខ 13 11 14 ឬផ្ញើសារមកលេខ 0477 13 11 14 សំរាប់ការជួយគាំទ្រ។*

# តើកញ្ចប់ឧបករណ៍នេះសំរាប់អ្នកណា

កញ្ចប់ឧបករណ៍នេះគឺសំរាប់អ្នកបើអ្នក:

- ជាឪពុកម្តាយ ឬអ្នកថែរក្សា ហើយ
- មានកូនទៅសាលាមធ្យមសិក្សាឬបឋមសិក្សាដែលមានពិការភាព។

# កញ្ចប់ឧបករណ៍នេះសំរាប់អ្វី

កញ្ចប់ឧបករណ៍នេះនឹងជួយអ្នក:

- អោយជំរាបបារម្ភអំពីការអប់រំឬសុវត្ថិភាពរបស់កូនអ្នកដល់សាលា
- បញ្ជូនបារម្ភរបស់អ្នកទៅចំអ្នកទទួលដោះស្រាយ
- លើកបារម្ភរបស់អ្នកទៅថ្នាក់លើបើអ្នកត្រូវការ។

លើកទៅថ្នាក់លើ មានន័យថាយកអ្វីមួយទៅថ្នាក់ខ្ពស់ជាងមុន។

កំណត់ចំណាំ: កញ្ចប់ឧបករណ៍នេះផ្តល់ឱវាទទូទៅ ហើយប្រហែលមិនត្រូវស្ថានភាពទាំងអស់ទេ។

# កញ្ចប់ឧបករណ៍នេះនិយាយពីអ្វីខ្លះ

កញ្ចប់ឧបករណ៍នេះបង្ហាញគ្រប់ជំហាននៃការជំរាបបារម្ភ និងការលើកតំអូញទៅថ្នាក់លើ។

វានិយាយពី:


- ច្បាប់រើសអើងពិការភាពអូស្ត្រាលី (ទ. 2)
- មុននឹងជំរាបបារម្ភ (ទ. 3)
- ជំហានជំរាបនិងលើកបារម្ភទៅថ្នាក់លើ (ទ. 6)
- ជំរាបបារម្ភរបស់អ្នកទៅសាលា (ទ. 6)
- លើកបារម្ភទៅថ្នាក់ខ្ពស់ជាងសាលា (ទ. 10)
- កន្លែងទទួលជំនួយនិងព័ត៌មាន (ទ. 16)

# ច្បាប់រើសអើងពិការភាពអូស្ត្រាលី

សិស្សទាំងអស់ដែលមានពិការភាពក្នុងប្រទេសអូស្ត្រាលី
ត្រូវបានការពារដោយ ***ច្បាប់រើសអើងពិការភាព1992*** (DDA) និង ***ស្តង់ដារពិការភាពសំរាប់ការអប់រំ2005*** (DSE)។ សាលាទាំងអស់ត្រូវអនុលោមតាម DDA និង DSE ។

## និយមន័យ: ច្បាប់រើសអើងពិការភាព1992 (DDA)

ច្បាប់ DDA ជាច្បាប់មួយសំរាប់ជនគ្រប់រូបនៅប្រទេសអូស្ត្រាលី។
វាកាពារមិនអោយមានការរើសអើងដោយសារពិការភាពរបស់គេ។

## និយមន័យ: ស្តង់ដារពិការភាពសំរាប់ការអប់រំ 2005 (DSE)

ច្បាប់ DSE ជាច្បាប់មួយចំនួនដែលស្ថិតនៅក្រោម DDA។ ច្បាប់ទាំងនេះបញ្ជាក់កាតព្វកិច្ចរបស់អ្នកផ្តល់ការអប់រំ។
ច្បាប់ DSE ប្រាប់អ្នកផ្តល់ការអប់រំទាំងឡាយថាគេត្រូវធ្វើយ៉ាងណាដើម្បីគាំទ្រសិស្សដែលមានពិការភាព។

សាលាទាំងឡាយអាចអនុលោមតាម ដោយធ្វើការផ្លាស់ប្តូរដែលគាំទ្រសិស្សដែលមានពិការភាព
ដើម្បីអោយចូលរួមក្នុងការអប់រំលើមូលដ្ឋានដូចគ្នានឹងមិត្តស្រករពួកគេដែរ។
ការផ្លាស់ប្តូរទាំងនេះហៅថាការកែសំរួលសមហេតុផល។ វាអាចជា:

- មនុស្ស ( ឧ. បុគ្គលិកជំនួយ )
- ឧបករណ៍ (ឧ. គ្រឿងអាន)
- ការផ្លាស់ប្តូរដល់របៀបធ្វើអ្វីមួយ (ឧ. ការឈប់សំរាក)។

ជាទូទៅ សាលាត្រូវធ្វើការផ្លាស់ប្តូរលុះត្រាណាវាបណ្តាលអោយមានភាពលំបាកហួសហេតុផល។
គេក៏ត្រូវធ្វើយ៉ាងណាអោយកូនអ្នកទទួលការអប់រំក្នុងបរិស្ថានដែលមានសុវត្ថិភាពផុតពីការយាយីនិងការធ្វើបាបផងដែរ។

អ្នកអាចស្វែងយល់ថែមអំពី DSE និងពាក្យសំខាន់ៗដូចជា ‘មូលដ្ឋានដូចគ្នា’, ‘ការកែសំរួលសមហេតុផល’ និង ‘ភាពលំបាកហួសហេតុផល’ ក្នុងធនធានរបស់យើង: ពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំ។

# មុននឹងជំរាបបារម្ភ

បើអ្នកបារម្ភឬគិតថាសាលារបស់កូនអ្នកមិនអនុលោមតាម DSE នោះអ្នកអាចពិគ្រោះការនេះជាមួយគេបាន។ អ្នកគួរធ្វើអោយបានលឿនតាមអាចធ្វើបាន។

មុននឹងជំរាបបារម្ភ សូមមើលសូមមើលដំណើរថ្លែងតំអូញសំរាប់សាលារបស់កូនអ្នក។ ធ្វើដូចនេះនឹងជួយអោយអ្នកដឹងថានឹងត្រូវនិយាយជាមួយអ្នកណា។ អ្នកអាចរកព័ត៌មាននេះនៅវែបសៃត៍របស់សាលា ឬសួរគេសុំមួយច្បាប់ក៏បាន។ យកល្អគួរចំណាយពេលវេលាខ្លះៗដើម្បីរៀបចំមុននឹងជំរាបពីបារម្ភឬតំអូញ។ យើងហៅការនេះថា ‘ការបង្ហាញករណីរបស់អ្នក’។

## ការបង្ហាញករណីរបស់អ្នក

អ្នកអាចប្រើគន្លឹះទាំងនេះដើម្បីជួយរៀបចំក្នុងការជំរាបបារម្ភ:

- *មានគោលដៅច្បាស់លាស់។* គិតអំពីអ្វីដែលអ្នកចង់អោយកើតឡើង។
- *ពិគ្រោះជាមួយកូនអ្នក។* សួរគាត់ថាគាត់គិតយ៉ាងណា ហើយថាគាត់ចង់បានអ្វីអោយកើតឡើង។ សួរថាគាត់ចង់លូកដៃចូលក្នុងដំណើរការនោះប៉ុណ្ណា។
- *ប្រមូលយកព័ត៌មានណាក៏ដោយ ឬក្រដាសស្នាមដែលអ្នកត្រូវការ ឬដែលនឹងមានប្រយោជន៍។* ឧ. សុំសំបុត្រមួយច្បាប់ពីគ្រូពេទ្យការងាររបស់កូនអ្នកដើម្បីយកមកចែករំលែកជាមួយសាលារបស់កូនអ្នក។
- *ចូរកត់ត្រាទុកពីអ្វីៗដែលកើតឡើង។* សរសេរទុក ទុកអ៊ីមេល ហើយសរសេរទុកអ្វីៗទាំងអស់ដែលអ្នកយល់ស្រប។ កត់ទុកថ្ងៃទី ការសន្ទនាគ្នា និងលទ្ធផលដែលបានយល់ព្រមគ្នាហើយ។
- *ស្វែងយល់ដឹងអំពី* DSE។ នេះរាប់ទាំងការដឹងពាក្យសំខាន់ៗដូចជា ‘ការកែសំរួលសមហេតុផល’, ‘មូលដ្ឋានដូចគ្នា’ និង ‘ភាពលំបាកហួសហេតុផល’។
  អ្នកអាចស្វែងយល់ថែមទៀតបានក្នុងធនធានរបស់យើង: ពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំ។
- *រកជំនួយបើអ្នកត្រូវការវា។* ឧ. នាំមិត្តម្នាក់មក ឬនាំ**អ្នកគាំទ្រឯករាជ្យ**មក។ សូមមើល ជំនួយលើការគាំទ្រ (ទ. 16).

## យកតំណែងរបស់ខ្លួន

យើងទាំងអស់គ្នាមានកាលៈទេសៈខុសគ្នា ដែលអាចធ្វើអោយងាយជាងឬពិបាកជាងក្នុងការដំរាបបារម្ភ។
កន្លែងយើងនៅ ធ្វើការ និងរស់ធំឡើងសុទ្ធតែប៉ះពាល់ដល់ការគិតអំពីការគាំទ្រអោយខ្លួនឯង។
ក៏ដូចគ្នានឹងរឿងភេទ ស្ថានភាពដៃគូ វប្បធម៌ និងសាសនាដែរ។
វាអាចប៉ះពាល់ដល់របៀបអ្នកដទៃតបមកអ្នក។
សំខាន់គឺត្រូវដឹងថាៈ

- អ្នកអាចដំរាបបារម្ភបានពេលអ្នកជឿថាមានអ្វីដែលមិនត្រូវ។
- សាលារបស់កូនអ្នកត្រូវធ្វើតាម DDA និង DSE ដែលជាច្បាប់អូស្ត្រាលី។ បើមិនដូច្នោះទេ អ្នកអាចសុំអោយគេធ្វើតាមបាន។
- អ្នក (និងកូនរបស់អ្នក) មិនគួរទទួលទណ្ឌកម្មចំពោះការនេះឡើយ។
- មានសេវាកម្មដែលជួយគាំទ្រអ្នក។ សូមមើល កន្លែងទទួលជំនួយនិងព័ត៌មាន (ទ.16)។

អ្នកអាចស្វែងយល់ថែមទៀតអំពីការការពារខ្លួនឯងក្នុងធនធានរបស់យើងៈ

- គាំទ្រអោយកូនអ្នកៈ វ័យដំបូង
- គាំទ្រជាមួយកូនអ្នក និងគាំទ្រអោយកូនអ្នកៈ មត្តេយ្យសាលា
- ធ្វើការជាមួយគ្នាៈ ឆ្លងទៅសាលាបឋមសិក្សា។

## គិតអំពីរបៀបដែលអ្នកទាក់ទងជាមួយសាលា

អ្នកគួរខិតខំរក្សាទំនាក់ទំនងល្អជាមួយសាលា។
នេះនឹងជួយអ្នកអោយសហការជាមួយបុគ្គលិកសាលាដើម្បីដោះស្រាយបារម្ភនានា។
អ្នកអាចប្រើគន្លឹះទាំងនេះដើម្បីជួយអ្នកទាក់ទាងតាមរបៀបដែលអ្នកពេញចិត្ត។

## គន្លឹះទាក់ទងសាលា

| គន្លឹះ | វាជួយយ៉ាងណា |
|---|---|
| ចូរផ្តោតទៅលើលទ្ធផលវិជ្ជមាន | ការពិគ្រោះជាមួយសាលាអំពីអ្វីដែលបានធ្វើខុស ឬអ្វីដែលមិនបានកើតឡើង គឺជាការសំខាន់។ សូមពន្យល់គេថាការផ្លាស់ប្តូរឬជំនួយដែលអ្នកសូមនឹងជួយកូនអ្នកយ៉ាងណា។ នេះនឹងជួយអោយសាលាយល់កូនអ្នកកាន់តែច្បាស់ជាងមុន ហើយនិងយល់គោលដៅរបស់គាត់សំរាប់ការអប់រំ។<br><br>ឧ. អ្នកប្រហែលប្រជុំពីព្រោះអ្នកបារម្ភពីការធ្វើតេស្តតើវាធ្វើទៅជាយ៉ាងណា។ ប៉ុន្តែគោលដៅរបស់អ្នកគឺចង់អោយកូនអ្នកបង្កើនជំនាញខាងការអានរបស់គាត់។<br><br>អ្នកគួរព្រាងគោលដៅសំរាប់ការអប់រំកូនជាមួយកូនអ្នក។ |
| ទទួលស្គាល់សាលា | សូមគិតពីទស្សនៈរបស់សាលាផងក្នុងពេលអ្នកប្រជុំ។ នេះនឹងជួយអោយអ្នកទាំងសងខាងចែករំលែកគំនិតគ្នាដោយក្តីគោរព។ អ្នកប្រហែលជាអាចរកគំនិតថ្មីៗរួមគ្នាបាន។ សូមជំរាបនូវអ្វីដែលសាលាបានធ្វើល្អ។ អ្នកប្រហែលជាអាចរៀនដឹងពីភាពជោគជ័យទាំងនេះ។ ប្រាប់គេពីចំណុចល្អខ្លះៗនឹងជួយធ្វើអោយអ្វីៗប្រសើរឡើង ជាជាងគ្រាន់តែនិយាយអំពីអ្វីដែលត្រូវការកែខៃ។ |
| ចូរសំគាល់មើលរបៀបដែលអ្នកនិយាយស្តីជាមួយបុគ្គលិកសាលា | នេះប៉ះពាល់ដល់ទំនាក់ទំនង។ វាអាចផ្លាស់ប្តូររបៀបដែលគេតបមកអ្នក។ ចូរបើកចំហចិត្ត មានចិត្តរួសរាយ ហើយផ្តោតទៅលើការស្តាបនា។ បើអ្នកមានអារម្មណ៍ធុញថប់ សូមរកវិធីល្អមួយដើម្បីបង្ហាញវា – ត្រូវប្រុងប្រយ័ត្នចំពោះអ្វីដែលអ្នកនិយាយនៅលើបណ្តាញ  សង្គម។ |
| នៅអោយស្ងៀម ហើយនឹងធឹង | នេះអាចពិបាកពេលអ្នកពិគ្រោះអំពីការអប់រំនិងសុខុមាលភាពរបស់កូនអ្នក។ ចូររកអ្វីដែលជួយអោយអ្នកមានអារម្មណ៍មូលល្អ។ ឧ. យកល្បែងលេង ឬរូបថតមកទុកជាការរំលឹក។ |
| ផ្តោតអារម្មណ៍ទៅលើសកម្មភាពដែលគេត្រូវធ្វើ មិនមែនលើមនុស្ស | អ្នកប្រហែលមានតំអូញដែលទាក់ទងនឹងសមាជិកបុគ្គលិកណាមួយ។ ប៉ុន្តែអ្នកត្រូវផ្តោតទៅលើអ្វីដែលអ្នកចង់អោយគេផ្លាស់ប្តូរ ឬធ្វើអោយប្រសើរឡើង មិនមែនលើអ្នកនោះជាមនុស្សបែបណាទេ។ |
| ដោះស្រាយបញ្ហាធំៗសិន | ប្រហែលមានបញ្ហាមួយទៀតដែលអ្នកកំពុងបារម្ភ។ វាមិនមែនជាចំណុចសំខាន់នៃការសន្ទនានេះទេ តែអ្នកត្រូវលើកមកនិយាយដោះស្រាយមុននឹងទៅមុខទៀត។ ឧ. សាលាប្រើឈ្មោះកូនអ្នកខុស។ |

អ្នកអាចរកគំនិតថែមទៀតក្នុង ធនធាន DSE ឯទៀតរបស់យើង។

# ជំហានជំរាបបារម្ភនិងលើកបារម្ភទៅថ្នាក់លើ

នៅខាងក្រោមគឺជាជំហានសំរាប់ជួយជំរាបនិងលើកបារម្ភអំពីការអប់រំកូនអ្នកទៅថ្នាក់លើ។ មានរៀបរាប់ពីឈ្មោះដែលអ្នកត្រូវទាក់ទងក្នុងដំណាក់កាលខុសៗគ្នានៃដំណើរការ។ នេះនឹងអាស្រ័យលើសាលាអ្នកនិងស្ថានភាព។ គ្រប់សាលាមានវិធីតបឆ្លើយនឹងតំអូញខុសៗគ្នា។ មុននឹងលើកបារម្ភទៅថ្នាក់លើ មុននឹងអ្នកជំរាបគេពីបារម្ភ សូមមើលដំណើរថ្លែងតំអូញសំរាប់សាលាកូនអ្នក។ ធ្វើដូចនេះនឹងជួយអោយអ្នកដឹងថានឹងត្រូវនិយាយជាមួយអ្នកណា។ អ្នកអាចរកព័ត៌មាននេះនៅវែបសៃត៍នៃសាលា ឬអ្នកអាចសុំគេមួយច្បាប់ក៏បាន។

**ដោះស្រាយក្នុងសាលា:**

**ជំហាន 1:** ជំរាបទៅគ្រូឬបុគ្គលិកអប់រំផ្សេងទៀត (ទ. 7)

**ជំហាន 2:** ជំរាបទៅអ្នកចាត់ចែងកំរិតថ្នាំសិក្សា ឬប្រធាននៃជំនួយសិក្សា (ទ. 9)

**ជំហាន 3:** ជំរាបទៅចាងហ្វាង (ទ. 10)

**លើកទៅថ្នាក់ខ្ពស់ជាងសាលា:**

**ជំហាន 4:** លើកទៅថ្នាក់ក្នុងប្រព័ន្ធអប់រំសាលា (ទ. 11)

**ជំហាន 5:** តួញត្អែទៅអាជ្ញាធរមួយទៀត (ទ. 13)

អ្នកប្រហែលជាធ្វើតាមជំហាននេះខ្លះៗរួចទៅហើយ។ ឬប្រហែលជានៅទីដើមនៃដំណើរការ។ អ្នកអាចផ្លោះទៅជំហានដែលស័ក្តិសមនឹងអ្នកបំផុត។

# ជំរាបបារម្ភទៅសាលា

អ្នកជំរាបបារម្ភរបស់អ្នកទៅអ្នកណានោះគឺអាស្រ័យទៅលើបារម្ភរបស់អ្នកស្តីពីអ្វី។ ក្នុងជំហានទីមួយ យកល្អព្យាយាមដោះស្រាយបារម្ភរបស់អ្នកដោយលើកមកជំរាបគ្រូរបស់កូនអ្នក។

អ្នកអាចប្រើជំហានខាងក្រោមដើម្បីរកអ្នកដែលសមបំផុតសំរាប់ស្ថានភាពរបស់អ្នក។ បើអ្នកមិនអាចដោះស្រាយបារម្ភជាមួយគេមិនបានទេ អ្នកអាចឈានទៅជំហានបន្ទាប់។

## ជំហាន 1: ជំរាបគ្រូនិងបុគ្គលិកអប់រំផ្សេងទៀត

តើបារម្ភរបស់អ្នកស្តីអំពីៈ

- អ្នកអប់រំណាមួយឬ ដូចជាគ្រូណាម្នាក់ឬ?
- មេរៀនណាមួយ ឬមាតិកានៃមេរៀនណាមួយឬ?
- ថ្នាក់រៀន ទីលែងកំសាន្ត ឬការរៀបចំដំណើរកំសាន្តឬ?
- សិស្សដទៃទៀតឬ?
- ការរាប់បញ្ចូលទូទៅឬ?

គ្រូប្រហែលជាអាចដោះស្រាយបញ្ហារបស់អ្នកផ្ទាល់។ វាអាចជាទង្វើងាយៗ ដូចជាផ្ញើអ៊ីមេល ឬទូរស័ព្ទមកការិយាល័យ។ ឬអ្នកប្រហែលត្រូវការប្រជុំដើម្បីពិគ្រោះគ្នាអោយបានពិស្តារថែមទៀត។

អ្នកប្រហែលជាត្រូវនិយាយជាមួយគេពីរបីដងទំរាំរកដំណោះស្រាយឃើញសំរាប់គ្រប់គ្នា។ អ្នកក៏អាចសាកវិធីផ្សេងៗដើម្បីរកចំឡើយដ៏ល្អបំផុតសំរាប់កូនអ្នក។ គ្រប់ការសំរេចចិត្តរបស់អ្នកគួរតែផ្តោតលើអ្វីដែលល្អបំផុតសម្រាប់កូនអ្នក។

**លទ្ធផលដ៏ល្អបំផុតបានសំរេចនៅពេលសិស្ស គ្រូ មាតាបិតា និងអ្នកថែរក្សាធ្វើការជាមួយគ្នា។**

បើអ្នកមានអារម្មណ៍មិនស្រួលក្នុងការជំរាបបារម្ភទៅគ្រូ ឬបើបញ្ហាស្តីអំពីសាលា នោះអ្នកអាចរំលង ជំហាន 2 (ទ.9) បាន។



## មុននឹងបោះជំហាន

1. សុំជួប
2. វាយបញ្ជីអំពីអ្វីដែលអ្នកចង់ពិគ្រោះ
3. រៀបចំរកជំនួយ (សូមមើល ទ. 16)

## បោះជំហាន

1. ចូរពន្យល់:
   a) ការប៉ះពាល់ដល់កូនអ្នក
   b) យោបល់នានាដែលអ្នកមាន
2. សន្ទនាជាមួយគ្រូដើម្បីចែករំលែកគំនិតគ្នា
3. សរសេរទុក ហើយគូសវាចេញពីបញ្ជី

## បន្ទាប់ពីបោះជំហាន

1. សរសេរអ៊ីមេលទៅគ្រប់គ្នាដើម្បី:
   a) អរគុណគេសំរាប់ពេលវេលាគេ
   b) សរុបអ្វីដែលកើតឡើងនៅក្នុងការប្រជុំ និងអ្វីដែលបានយល់ព្រមគ្នា
2. រក្សាការទាក់ទងគ្នា
3. ចូរចាំថា ការផ្លាស់ប្តូរខ្លះត្រូវចំណាយពេលយូរទំរាំនឹងបានចាប់ផ្តើមធ្វើ
4. ឆែកមើលក្រែងលោការផ្លាស់ប្តូរ:
   a) ត្រូវបានធ្វើហើយ
   b) កំពុងមានដំណើរការ។

**គន្លឹះ:** កត់ទុកពេលតាំងពីសុំជួប ឬតាំងពីជួបដំបូងថាតើវាយូរប៉ុណ្ណាហើយ។ គំនិតល្អមួយគឺត្រូវយល់ព្រមគ្នាលើពេលកំណត់ដើម្បីអោយអ្វីៗកើតឡើង។ ធ្វើដូច្នេះគ្រប់គ្នាក្នុងក្រុមសាលាអាចនាំគ្នាធ្វើការឆ្ពោះទៅរកពេលកំណត់នោះ។

## ជំហាន 2: ជំរាបទៅអ្នកចាត់ចែងកំរិតឆ្នាំសិក្សា ឬប្រធានជំនួយសិក្សា

ជួនកាលបារម្ភរបស់អ្នកប្រហែលជាធំជាងថ្នាក់រៀន ឬគ្រូម្នាក់។ អ្នកគួរទាក់ទងអ្នកចាត់ចែងកំរិតឆ្នាំសិក្សា ឬប្រធានជំនួយសិក្សា បើបារម្ភរបស់អ្នក:

- ត្រូវការផ្លាស់ប្តូរផ្នែកជាច្រើនក្នុងជីវិតសាលារបស់កូនអ្នក
- ពាក់ព័ន្ធនឹងសិស្សម្នាក់ទៀតឬគ្រួសាររបស់គេ។

អ្នកចាត់ចែងកំរិតឆ្នាំសិក្សារបស់កូនអ្នក អាចធ្វើការផ្លាស់ប្តូរដល់គំរោងអប់រំផ្ទាល់ខ្លួនរបស់កូនអ្នក ផ្ញើសារទៅគ្រូរបស់កូនអ្នក ឬជួបជាមួយសិស្សម្នាក់ទៀត។

អ្នកប្រហែលត្រូវការទៅសមាជិកម្នាក់ទៀតនៃក្រុមដឹកនាំសាលា។ អ្នកណាដែលអ្នកសំរេចចិត្តនិយាយជាមួយនឹងអាស្រ័យទៅលើ:

- ច្បាប់តំអូញរបស់សាលា (អ្នកអាចមើលវែបសៃត៍របស់សាលា ឬសុំគេមួយច្បាប់)
- បទពិសោធន៍អតីតជាមួយបុគ្គលិកសំខាន់ៗ
- បារម្ភធំ ឬបន្ទាន់ប៉ុណ្ណា។

## បោះជំហាន

1. សូមប្រាប់គេ:
   a) ពីបារម្ភរបស់អ្នក
   b) ថាមានប៉ះពាល់អ្វីខ្លះ
   c) ថាធ្វើបានអ្វីខ្លះហើយ
   d) ថាអ្នកចង់បានអ្វី

2. យល់ព្រមដល់គំរោងសំរាប់:
   a) អ្វីដែលនឹងកើតឡើង
   b) អ្នកដែលនឹងធ្វើ
   c) ពេលណាដែលវានឹងកើតឡើង

3. ចាំសួរបុគ្គលិកលើកក្រោយទៀត

## ជំហាន 3: ជំរាបចាងហ្វាង

តើបារម្ភរបស់អ្នក:

- ពាក់ព័ន្ធនឹងសមាជិកបុគ្គលិកឯទៀតឬទេ?
- ពាក់ព័ន្ធនឹងសិស្សឯទៀត ឬគ្រួសាររបស់គេឬទេ?
- ត្រូវការផ្លាស់ប្តូររបៀបសាលាធ្វើដំណើរការឬទេ?
- ត្រូវការផ្លាស់ប្តូរដល់អាគារសាលា ឬទីលានសាលាឬទេ?

បើមាន សូមលើកបារម្ភអ្នកមកជំរាបចាងហ្វាងសាលា។

អ្នកអាចធ្វើតាមឱវាទពី ជំហាន 1 (ទ. 7) និង ជំហាន 2 (ទ. 9) ដើម្បីជួយជំរាបបារម្ភទៅចាងហ្វាងសាលា។

# លើកបារម្ភរបស់អ្នកទៅហួសពីសាលា

ក្នុងករណីខ្លះ អ្នកនិងសាលារបស់កូនអ្នកប្រហែលអាចរកចំឡើយមួយឃើញ។ ក្នុងករណីផ្សេងទៀត អ្នកប្រហែលមិនត្រូវការលើកបារម្ភទៅថ្នាក់លើទេពីព្រោះ:

- អ្នកមិនយល់ស្របគ្នា ឬពេលកំណត់ដែលអ្នកបានធ្វើឡើងជាមួយសាលាបានកន្លងហួសទៅហើយ
- សាលានិយាយថាអ្វីដែលអ្នកត្រូវការអោយគេធ្វើ សាលាធ្វើមិនបានទេ
- គេបានពិនិត្យសើរើការសំរេចក្តីមួយ ហើយអ្នកមិនពេញចិត្តនឹងលទ្ធផលនោះ។

### និយមន័យ: លើកទៅថ្នាក់លើ

ពេលអ្នកលើកបារម្ភទៅថ្នាក់លើ នោះមានន័យថាអ្នកយកវាទៅមួយជំណាក់ទៀត។

ឧទាហរណ៍ នេះអាចជាលើកទៅសមាជិកបុគ្គលិកណាម្នាក់ដែលចំណានជាង ឬទៅ**អង្គការផ្នែកតំអូញ**។

### និយមន័យ: អង្គការផ្នែកតំអូញ

អង្គការផ្នែកតំអូញជាអង្គការឯករាជ្យមួយដែលចាត់ការអំពីបារម្ភនិងតំអូញ។

## ជំហាន 4: លើកទៅថ្នាក់លើក្នុងប្រព័ន្ធអប់រំសាលា

អ្នកអាចជំរាបតំអូញរបស់អ្នកទៅក្រុមឬអង្គការដែលគ្រប់គ្រងលើសាលា។ ជួនកាលគេហៅថាអាជ្ញាធរអប់រំ។ នេះអាចជារដ្ឋឬក្រសួងអប់រំរបស់អនុរដ្ឋ គណៈកម្មាធិការសាលា ឬភូមិភាគ (ដូចជាភូមិភាគកាតូលិក)។

អ្នកប្រហែលអាចសុំអោយគេពិនិត្យសើរើសេចក្តីសំរេចចិត្តរបស់សាលាឡើងវិញ។

ជំហាននេះគឺខុសគ្នាសំរាប់សាលារដ្ឋនិងសាលាក្រៅពីរដ្ឋ។ ប៉ុន្តែសាលាទាំងអស់ត្រូវអនុលោមតាម DSE ។

សាលាអ្នកអាចផ្តល់ព័ត៌មានលំអិតអំពីរបៀបជំរាបបារម្ភ ឬដាក់ពាក្យតំអូញទៅអាជ្ញាធរអប់រំ។

កំណត់ចំណាំ: ជួនកាលការជំរាបបារម្ភទៅគណៈកម្មាធិការសាលាជាផ្នែកមួយនៃដំណើរដាក់ពាក្យតំអូញរបស់សាលា។

## អ្វីដែលអ្នកត្រូវធ្វើ

1. មើលរបៀបដាក់ពាក្យតំអូញរបស់សាលា

2. សំរេចចិត្តថានឹងដាក់ពាក្យតំអូញទៅអ្នកណា

3. ប្រមូលព័ត៌មាន:
ក) ដែលគេនឹងសួរចង់បាន
ខ) ដែលនឹងផ្តល់ភាពពិស្តារគ្រប់គ្រាន់
ដែលនឹងផ្តល់ភាពពិស្តារគ្រប់គ្រាន់

4. ផ្តោតទៅលើបារម្ភចំបងរបស់អ្នក

5. ជំរាបតំអូញហើយកត់ត្រាទុក

6. កត់ថ្ងៃសំខាន់ៗក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃ

7. រង់ចាំចំឡើយ

8. ព្យាយាមសំរុះសំរួលគ្នា

9. (បើមិនកើតទេ) គិតអំពីវិធីផ្សេងទៀត

មុននឹងអ្នកត្អូញត្អែរដាក់អ្នកណា សូមឆែកមើលសិនថាតើគេអាចដោះស្រាយតំអូញប្រភេទណាខ្លះ។ អ្នកប្រហែលត្រូវរកឱកាសថែមទៀតមុននឹងលើកទៅថ្នាក់ហួសសាលា បើអ្នកមិនទាន់បានធ្វើនៅឡើយទេនោះ។ សូមមើល កន្លែងទទួលជំនួយនិងព័ត៌មាន (ទ. 16).

**អ្នកដែលត្រូវទាក់ទងក្នុងប្រព័ន្ធអប់រំសាលា**

| ប្រភេទសាលា | ទាក់ទងអ្នកណា | ហេតុអ្វី |
| --- | --- | --- |
| សាលារដ្ឋ | ទាក់ទងក្រសួងអប់រំក្នុងរដ្ឋឬអនុរដ្ឋរបស់អ្នក។<br><br>អ្នកអាចទាក់ទងតាមអនឡាញឬតាមការិយាល័យរបស់គេ។<br><br>រដ្ឋខ្លះ និងអនុរដ្ឋមានការិយាល័យប្រចាំតំបន់ ឬស្រុកដែលអ្នកអាចទាក់ទងជាមុនសិន។ បើគេមិនអាចជួយទេ អ្នកអាចទាក់ទងការិយាល័យទីស្នាក់ការ។<br><br>សំរាប់ព័ត៌មានបន្ថែម សូមមើល ឈ្មោះទាក់ទងប្រចាំរដ្ឋនិងអនុរដ្ឋ (ទ. 19). | សាលារដ្ឋគឺត្រូវបានចាត់ចែងដោយក្រសួងអប់រំប្រចាំរដ្ឋឬអនុរដ្ឋ។ |
| សាលាក្រៅពីរដ្ឋ - កាតូលិក ឬឯករាជ្យ | ទាក់ទងអង្គការដែលទទួលខុសត្រូវសំរាប់សាលាអ្នក – ឧ. គណៈកម្មាធិការសាលាសំរាប់សាលាឯករាជ្យ ឬសាលាកាតូលិកប្រចាំតំបន់។<br><br>បើរដ្ឋឬអនុរដ្ឋរបស់អ្នកមានអង្គការផ្នែកតំអូញសំរាប់សាលាក្រៅពីរដ្ឋ នោះអ្នកអាចទាក់ទងទៅនោះមុនសិន។ | សាលាក្រៅពីរដ្ឋគឺចាត់ចែងដោយអង្គការផ្សេងទៀត។ ឧទាហរណ៍ មានសាលាសាសនា និងសាលាឯករាជ្យ។<br><br>រដ្ឋនិងអុរដ្ឋខ្លះមានអង្គការផ្នែកតំអូញសំរាប់សាលាក្រៅពីរដ្ឋ។<br><br>អង្គការទាំងនេះអាចជំរាបជំណោះស្រាយទៅសាលា។ |

## ជំហាន 5: តួញត្អែទៅអាជ្ញាធរផ្សេងទៀត

អ្នកអាចដាក់ពាក្យតំអូញទៅអាជ្ញាធរផ្សេងទៀតប្រសិនបើអ្នកៈ

- មិនអាចដោះស្រាយបារម្ភរបស់អ្នកនឹងជំហានមុន ហើយ/ឬ
- ជឿថាគេបានរើសអើងដល់កូនអ្នក។

នេះអាចជាគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី ឬអាជ្ញាធរប្រឆាំងនឹងការរើសអើងក្នុងរដ្ឋឬអនុរដ្ឋរបស់អ្នក។

### និយមន័យ: ការរើសអើង

ការរើសអើងលើពិការភាពគឺខុសច្បាប់។ វាមានន័យថាៈ

- មនុស្សម្នាក់ត្រូវបានគេប្រព្រឹត្តមកលើយ៉ាងអាក្រក់ជាងពេលដែលគេមិនពិការ។
- មនុស្សម្នាក់ត្រូវធ្វើអ្វីមួយដែលគេមិនអាចធ្វើដោយព្រោះពិការភាពរបស់គេ ហើយការផ្លាស់ប្តូរក៏មិនមានទៀត។

អ្នកអាចស្វែងយល់ថែមទៀតក្នុងធនធានរបស់យើងៈ ពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំ។ .

### គណៈកម្មការសិទ្ធិមនុស្ស (AHRC)

AHRC ជាអង្គការឯករាជ្យ។ វាស៊ើបអង្កេតតំអូញអំពីការរើសអើងខុសច្បាប់ក្រោម DDA ឬ DSE។

តើខ្ញុំដាក់ពាក្យតំអូញដូចម្តេច?

AHRC មានព័ត៌មានពីរបៀបដាក់ពាក្យតំអូញនៅវែបសៃត៍របស់គេ (https://humanrights.gov.au).

បើអ្នកមិនច្បាស់ថាអ្នកអាចដាក់ពាក្យតំអូញអំពីអ្វីមួយ អ្នកអាចទាក់ទងសេវាកម្មព័ត៌មានតំអូញនៃAHRC:

- តាមទូរស័ព្ទលេខ 1300 656 419
- តាមអ៊ីមេល infoservice@humanrights.gov.au.

## ភ្នាក់ងារប្រឆាំងនឹងការរើសអើងប្រចាំរដ្ឋនិងអនុរដ្ឋ

រដ្ឋនិងអនុរដ្ឋទាំងអស់មានច្បាប់ប្រឆាំងនឹងការរើសអើង និង/ឬ សិទ្ធិមនុស្ស និងឱកាសស្មើភាព។ អាស្រ័យលើកាលៈទេសៈរបស់អ្នក អ្នកអាចសំរេចចិត្តដាក់ពាក្យតំអូញក្រោមច្បាប់របស់រដ្ឋឬអនុរដ្ឋរបស់អ្នក។

សំរាប់ព័ត៌មានបន្ថែម សូមអញ្ជើញទៅមើលវែបសៃត៍ភ្នាក់ងារប្រឆាំងនឹងការរើសអើងសំរាប់រដ្ឋឬអនុរដ្ឋរបស់អ្នក។

សូមមើល ឈ្មោះទាក់ទងប្រចាំរដ្ឋនិងអនុរដ្ឋ (ទ. 19) សំរាប់តំណទៅវែបសៃត៍របស់គេ។

## អ្នកស៊ើបអង្កេតតំអូញប្រចាំរដ្ឋនិងអនុរដ្ឋ

អាស្រ័យលើស្ថានភាពរបស់អ្នក អ្នកអាចដាក់ពាក្យតំអូញទៅអ្នកស៊ើបអង្កេតតំអូញក្នុងរដ្ឋ ឬអនុរដ្ឋរបស់អ្នក។ គេអាចមើលថាតើតំអូញរបស់អ្នកត្រូវបានចាត់ការត្រឹមត្រូវឬអត់ក្នុងសាលារដ្ឋ។ យ៉ាងណាក៏ដោយ គេមិនអាចៈ

- ស៊ើបអង្កេតឬដោះស្រាយតំអូញលើការរើសអើងផ្ទាល់នោះទេ
- បដិសេធការសំរេចរបស់សាលារបស់អ្នកឡើយ។

សំរាប់ព័ត៌មានបន្ថែម សូមអញ្ជើញទៅមើលវែបសៃត៍របស់អ្នកស៊ើបអង្កេតសំរាប់រដ្ឋឬអនុរដ្ឋរបស់អ្នក (សូមមើល ទ. 19 សំរាប់តំណទៅវែបសៃត៍)។

## \សង្ខេបៈ ជំហានទាំង 5 ដើម្បីលើកតំអូញរបស់អ្នកទៅថ្នាក់លើ

**ជំហាន 1**

(ទ. 7)

**ជំរាបបារម្ភរបស់អ្នកទៅគ្រូ ឬបុគ្គលិកអប់រំផ្សេងទៀត**

ចូរធ្វើតាមច្បាប់តំអូញនៃសាលារបស់កូនអ្នក
ហើយបើបារម្ភរបស់អ្នកត្រូវការដោះស្រាយដោយអ្នកដែលចំណានជាងគ្រូរបស់កូនអ្នក នោះចូរទៅជំហានទី2 ។

**ជំហាន 2**

(ទ. 9)

**ជំរាបបារម្ភរបស់អ្នកទៅអ្នកចាត់ចែងកំរិតថ្នាំសិក្សា ឬប្រធានជំនួយលើការសិក្សា**

អ្នកចាត់ចែងកំរិតថ្នាំសិក្សារបស់កូនអ្នកអាចធ្វើការផ្លាស់ប្តូរដល់គំរោងអប់រំផ្ទាល់ខ្លួនរបស់កូនអ្នក ផ្ញើសារទៅគ្រូរបស់កូនអ្នក ឬជួបជាមួយសិស្សម្នាក់ទៀត។

**ជំហាន 3**

(ទ. 10)

**ជំរាបបារម្ភរបស់អ្នកទៅចាងហ្វាង**

បើបារម្ភរបស់អ្នកទាក់ទងនឹងសមាជិកបុគ្គលិកដទៃទៀត ឬសិស្ស
ឬត្រូវការផ្លាស់ប្តូរដល់ប្រតិបត្តិការរបស់សាលា សំណង់ ឬទីលាន
នោះសូមជំរាបបារម្ភរបស់អ្នកទៅចាងហ្វាងសាលា។

**ជំហាន 4**

(ទ. 11)

**ដាក់ពាក្យតំអូញទៅអាជ្ញាធរអប់រំ**

បើបារម្ភរបស់អ្នកមិនអាចដោះស្រាយក្នុងសាលារបស់អ្នកទេ
អ្នកអាចយកទៅអាជ្ញាធរដែលគ្រប់គ្រងសាលា។

កំណត់ចំណាំ:
ជំហាននេះគឺខុសគ្នាសំរាប់សាលារដ្ឋនិងសាលាក្រៅពីរដ្ឋ។

**ជំហាន 5**

(ទ. 13)

**ដាក់ពាក្យតំអូញ ឬសុំអោយអាជ្ញាធរផ្សេងទៀតពិនិត្យសើរើ**

បើតំអូញរបស់អ្នកមិនអាចដោះស្រាយទេ
ឬអ្នកជឿថាកូនអ្នកត្រូវបានគេរើសអើង
នោះអ្នកអាចដាក់ពាក្យតំអូញទៅអាជ្ញាធរផ្សេងទៀត។

នេះអាចជា:
- អ្នកស៊ើបអង្កេតតំអូញ
- អាជ្ញាធរប្រឆាំងការរើសអើង។

# កន្លែងទទួលជំនួយនិងព័ត៌មាន

អ្នកមិនបាច់ធ្វើអ្វីទាំងអស់ដោយខ្លួនឯងទេ។
អ្នកអាចសុំមិត្តភក្តិឬអ្នកជំនួយម្នាក់មកជួយអ្នករៀបចំការប្រជុំឬបំពេញហ្វម។
គេក៏អាចទៅប្រជុំជាមួយអ្នកផងដែរ។

## ជំនួយលើការគាំទ្រ

អ្នកអាចទទួលជំនួយពីអ្នកមានវិជ្ជាជីវៈម្នាក់ពី**អ្នកគាំទ្រឯករាជ្យ**។

### អ្នកគាំទ្រឯករាជ្យ

អ្នកគាំទ្រឯករាជ្យជាអ្នកដែលបានទទួលការហ្វឹកហ្វឺនឯកទេស
និងមានចំណេះឯកទេសដើម្បីជួយអ្នកដាក់ពាក្យតំអូញ។ គេអាចៈ

- ពន្យល់ដំណើរការអោយអ្នក
- ជួយអ្នកគិតអំពីគោលដៅរបស់អ្នក
- ជួយអ្នកខាងក្រដាសស្នាមនិងហ្វម
- ទៅប្រជុំជាមួយអ្នក
- ទាក់ទងអ្នកផ្តល់ការអប់រំជំនួសអ្នក។

មានសេវាកម្មគាំទ្រឥតគិតថ្លៃនិងតំលៃទាបជាច្រើនទូទាំងអូស្ត្រាលី
ដែលអ្នកអាចរកអ្នកគាំទ្រឯករាជ្យបាន។ សូមស្វែងរកសេវាកម្មដែលត្រូវនឹងតំរូវការរបស់អ្នកនៅៈ

- ច្រកផ្លូវពិការភាព (disabilitygateway.gov.au/legal/advocacy)
- បណ្តាញគាំទ្រពិការភាពអូស្ត្រាលី (dana.org.au/find-an-advocate)

អាស្រ័យលើកាលៈទេសៈរបស់អ្នក អ្នកប្រហែលអាចទទួលសេវាកម្មច្បាប់និងឱវាទដោយឥតគិតថ្លៃ
ឬដ៏មានតំលៃទាប។ សូមស្រាវជ្រាវមើលនៅៈ

- ច្រកផ្លូវពិការភាព (disabilitygateway.gov.au/legal/legal-services)
- មជ្ឈមណ្ឌលច្បាប់សហគមន៍អូស្ត្រាលី (clcs.org.au/legal-help)
- មជ្ឈមណ្ឌលការងារច្បាប់ឥតគិតថ្លៃអូស្ត្រាលី (probonocentre.org.au/legal-help).

## ជំនួយលើការទាក់ទង

| សេវាកម្មបកប្រែនិងបកប្រែផ្ទាល់មាត់ | សេវាកម្មបញ្ជូនតប្រចាំជាតិ | សេវាកម្មបកប្រែឥតគិតថ្លៃ |
|---|---|---|
| គេអាចជួយបានបើអ្នកមិនចេះនិយាយភាសាអង់គ្លេស។<br>• ទូរស័ព្ទ: **131 450**<br>• វែបសៃត៍: https://www.tisnational.gov.au | គេអាចជួយបានបើអ្នកត្រូវការសំឡេងទៅសារ សារទៅសំឡេង Auslan ទៅអង់គ្លេស ឬអង់គ្លេសទៅAuslan ។<br>• ទូរស័ព្ទ: **1300 555 727** (និយាយនិងស្តាប់)<br>• វែបសៃត៍: https://www.accesshub.gov.au | គេអាចបកប្រែឯកសារសំខាន់ផ្ទាល់ខ្លួន។<br>សូមទៅមើលវែបសៃត៍ដើម្បីអោយបានដឹងថានរណាអាចប្រើសេវាកម្មនេះបាន។<br>• ទូរស័ព្ទ: **1800 962 100**<br>• វែបសៃត៍: https://translating.homeaffairs.gov.au |

## ជំនួយផ្នែកសុខុមាលភាព

អ្នកគួររកជំនួយក្នុងពេលដែលអ្នកគិតថាអ្នកប្រហែលត្រូវការជំនួយ។
អ្នកមិនចាំបាច់ចាំដល់មានវិបត្តិទេមុននឹងសួររកជំនួយ។

### ជំនួយសំរាប់មាតាបិតានិងអ្នកថែរក្សា

- ច្រកផ្លូវអ្នកថែរក្សា (https://www.carergateway.gov.au)
- លេខទូរស័ព្ទជំនួយសំរាប់មាតាបិតានិងអ្នកថែរក្សា (https://raisingchildren.net.au/grown-ups/services-support/about-services-support/helplines)
- បណ្តាញចិញ្ចឹមកូន (https://raisingchildren.net.au)

### អ្នកជំនួយផ្នែកសុខភាពផ្លូវចិត្តនិងការអោយឱវាទតាមទូរស័ព្ទ សារឬអនឡាញ

- មូលនិធិ Blue Knot (https://blueknot.org.au)
- លៃហ្វ៍ឡាញ (https://www.lifeline.org.au)
- ប៊ីយ៉ន់ប្លូ (https://www.beyondblue.org.au)
- Yarning Safe'N'Strong (https://www.vahs.org.au/yarning-safenstrong)
- QLife (https://qlife.org.au)
- លេខទូរស័ព្ទជំនួយសំរាប់កុមារ (https://kidshelpline.com.au)

## ព័ត៌មានបន្ថែម

- សហព័ន្ធនៃអង្គការពិការភាពអូស្ត្រាលី (https://www.afdo.org.au)
- កុមារនិងយុវជនពិការនៅអូស្ត្រាលី (https://www.cyda.org.au)
- មជ្ឈមណ្ឌលពិការភាពអូស្ត្រាលី(https://www.disabilityaustraliahub.com.au)
- ច្រកផ្លូវពិការភាព (https://www.disabilitygateway.gov.au)
- បណ្តាញពិការភាពជនជាតិដើម (https://fpdn.org.au)
- ការរួមបញ្ចូលអូស្ត្រាលី (https://www.inclusionaustralia.org.au)
- សម្ព័ន្ធពិការភាពជាតិសាសន៍ (https://www.neda.org.au)
- ជនមានពិការភាពនៅអូស្ត្រាលី (https://pwd.org.au)
- SNAICC (https://www.snaicc.org.au)
- ស្ត្រីមានពិការភាពនៅអូស្ត្រាលី (https://wwda.org.au)

# ឈ្មោះទាក់ទងប្រចាំរដ្ឋនិងអនុរដ្ឋ

| រដ្ឋ/អនុរដ្ឋ | ក្រសួងអប់រំ | អ្នកស៊ើបអង្កេតតំអូញ | គណៈកម្មការសិទ្ធិមនុស្ស |
|---|---|---|---|
| អនុរដ្ឋរាជធានីអូស្ត្រាលី (ACT) | នាយកដ្ឋានអប់រំ ACT: https://www.education.act.gov. au | https://www.ombudsman.act.gov.au | https://hrc.act.gov. au |
| ញូសៅវែលស៍ (NSW) | ក្រសួងអប់រំនៃរដ្ឋាភិបាលញូសៅវែលស៍ : https://education.nsw.gov.au/ | https://www.ombo.nsw.gov. au | https://antidiscrimination.nsw.gov.au |
| អនុរដ្ឋខាងជើង(NT) | ក្រសួងអប់រំនៃរដ្ឋាភិបាល NT: https:// education.nt.gov.au | https://www.ombudsman.nt.gov.au | https://adc.nt.gov. au |
|ឃ្វីនសាឡែន | ក្រសួងអប់រំឃ្វីនសាឡែន: https://education.qld.gov.au | https://www.ombudsman.qld.gov.au | https://www.qhrc.qld.gov.au |
| អូស្ត្រាលីខាងត្បូង | ក្រសួងសំរាប់អប់រំអូស្ត្រាលីខាងត្បូង: https://www.education.sa.gov.au | https://www.ombudsman.sa.gov.au | https://www.equalopportunity.sa.gov.au |
| ថែសមេនា | ក្រសួងសំរាប់អប់រំកុមារនិងយុវជនថែសមេនា: https://www.decyp.tas.gov.au | https://www.ombudsman.tas.gov.au | https:// equalopportunity.tas.gov.au/home |
| វិចតូរៀ | ក្រសួងអប់រំវិចតូរៀ: https://www.education.vic.gov.au/ | https://www.ombudsman.vic.gov.au/ | https://www.humanrights.vic. gov.au/ |
| អូស្ត្រាលីខាងលិច | ក្រសួងអប់រំអូស្ត្រាលីខាងលិច: https://www.education.wa.edu.au | https://www.ombudsman.wa.gov.au | https://www.wa.gov.au/organisation/ equal-opportunity-commission |

https://www.education.gov.au/disability-standards-education-2005/ information-resources-students-disability-and-their-caregivers